ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង : ១៤៧/០៩-តាកប្លាត

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៧នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: កៅ ថាច

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: វិន កៅ

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: គង់ ផល្លះ

## ភាគីវិវាទ

១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន តាក ប្លាត ប្លាមីន (ខេមបូឌា) អិលធីឌី

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៦២៦ ៨៦៨ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក ហ៊ំ ភា មេធាវីក្រុមហ៊ុន

២- លោក រ៉ែម វីរៈ ជំនួយការមេធាវី

២- ភាគីកម្មករនិយោជិត

ក- ឈ្មោះ : សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា - សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជានៃក្រុមហ៊ុន តាកប្លាត ប្លាមីន

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៨២១ ៧១៣ លេខទូរសារ : គ្មាន

មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣

Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phnom Penh • Tel/Fax: 023 220 793

Email: secretariat@arbitrationcouncil.org• Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិត:

១- លោក ឯក សុភក្តិ មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា

២- លោក មាស សម្ផស្ស ប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ប្រចាំក្រុមហ៊ុន

៣- លោក លី វណ្ណរ៉ូ អនុប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ

៤- លោក យ៉ាន ចន្ទី លេខាសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ

៥- លោក សេង ណារិទ្ធិ ទីប្រឹក្សាសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ

៦- កញ្ញា ង៉ូវ មុយនី ទីប្រឹក្សាសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ

**ខ-ឈ្មោះ : សហព័ន្ធសហជីពកម្មករកម្ពុជា-សហជីពកម្មករនិយោជិតនៃក្រុមហ៊ុន តាកហ្វាត ហ្គាមិន**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១១ ៦៨ ៥៨ ២៦ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក សេង ម៉េងហុង មន្ត្រីសហព័ន្ធសហជីពកម្មករកម្ពុជា

២- កញ្ញា អ៊ុំ ផល្លា ប្រធានសហជីពកម្មករនិយោជិតប្រចាំក្រុមហ៊ុន

៣- លោក ម៉ា សុភាព អនុប្រធានសហជីពកម្មករនិយោជិតប្រចាំក្រុមហ៊ុន

៤- លោក យ៉ែម ចិន្តា ទីប្រឹក្សាសហជីពកម្មករនិយោជិតប្រចាំក្រុមហ៊ុន

៥- កញ្ញា ណាវ ទិត្យាវី ទីប្រឹក្សាទី២ សហជីពកម្មករនិយោជិតប្រចាំក្រុមហ៊ុន

**គ-ឈ្មោះ : សហព័ន្ធសហជីព-សហជីពយុវជនខ្មែរនៃក្រុមហ៊ុន តាកហ្វាត ហ្គាមិន**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៨២១ ៧១៣ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក សំ ចិត្រា ប្រធានសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន

២- លោក ជឿង រីម អនុប្រធានសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន

**ឃ-ឈ្មោះ : សហព័ន្ធសហជីព-សហជីពកម្មករអាស៊ីនៃក្រុមហ៊ុន តាកហ្វាត ហ្គាមិន**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៨២១ ៧១៣ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក ទួន ចន្ថា ប្រធានសហព័ន្ធសហជីពកម្មករអាស៊ី

| | |
|---|---|
| ២- កញ្ញា ស៊ិន សម្ផស្ស | ប្រធានសហជីពកម្មករអាស៊ី ប្រចាំក្រុមហ៊ុន |
| ៣- កញ្ញា រ៉ិត ចាន់ណា | អនុប្រធានសហជីពកម្មករអាស៊ី ប្រចាំក្រុមហ៊ុន |
| ៤- កញ្ញា គង់ ជីវ៉ា | លេខាសហជីពកម្មករអាស៊ីប្រចាំក្រុមហ៊ុន |

**ង-ឈ្មោះ : សហព័ន្ធសហជីព-សហជីពពន្លឺថ្មីនៃក្រុមហ៊ុន តាកហ្វាត ហ្គាមិន**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៨២១ ៧១៣ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

| | |
|---|---|
| ១- លោក គឹម ឌិច | ប្រធានសហជីពពន្លឺថ្មីប្រចាំក្រុមហ៊ុន |
| ២- លោក ឈា សារ៉ាវុធ | អនុប្រធានសហជីពពន្លឺថ្មីប្រចាំក្រុមហ៊ុន |
| ៣- កញ្ញា ម៉ៃ ស្រីអូន | លេខាសហជីពពន្លឺថ្មីប្រចាំក្រុមហ៊ុន |
| ៤- លោក រុំ សារ៉ុម | ទីប្រឹក្សាសហជីពពន្លឺថ្មីប្រចាំក្រុមហ៊ុន |

**ច-ឈ្មោះ : សហព័ន្ធសហជីព-សហជីពអភិវឌ្ឍន៍កម្មករកាត់ដេរនៃក្រុមហ៊ុន តាកហ្វាត ហ្គាមិន**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៨២១ ៧១៣ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

| | |
|---|---|
| ១- លោក សុំ ស៊ីន | ប្រធានសហជីពអភិវឌ្ឍន៍កម្មករកាត់ដេរប្រចាំក្រុមហ៊ុន |
| ២- កញ្ញា គង់ អេលីណា | ទីប្រឹក្សាសហជីពអភិវឌ្ឍន៍កម្មករកាត់ដេរប្រចាំក្រុមហ៊ុន |
| ៣- កញ្ញា ចាន់ សុជាតិ | ទីប្រឹក្សាសហជីពអភិវឌ្ឍន៍កម្មករកាត់ដេរប្រចាំក្រុមហ៊ុន |
| ៤- កញ្ញា យ៉ែម សុភាន់ | ទីប្រឹក្សាសហជីពអភិវឌ្ឍន៍កម្មករកាត់ដេរប្រចាំក្រុមហ៊ុន |

**ឆ-ឈ្មោះ : សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា នៃក្រុមហ៊ុន តាកហ្វាត ហ្គាមេន**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៨២១ ៧១៣ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

| | |
|---|---|
| ១- កញ្ញា សូត្រ ចន្ធូ | មន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា |
| ២- កញ្ញា យ៉ុង លោភ | ប្រធានសហជីពសេរីកម្មករប្រចាំក្រុមហ៊ុន |

# បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

កម្មករនិយោជិតនៃក្រុមហ៊ុន តាកហ្វាត នៅតែទាមទារឱ្យក្រុមហ៊ុនរំលាយកិច្ចសន្យាការងាររបស់បងប្អូនកម្មករនិយោជិត ដោយឱ្យក្រុមហ៊ុនផ្តល់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារ យោងតាមមាត្រា ៧៥, ៧៧, ៨៩, ៩១, ១១៦, ១៦៦ និង ១៦៧ នៃច្បាប់ស្តីពីការងារ ដោយមានហេតុផលដូចតទៅ:

១- ក្រុមហ៊ុនបានឈប់ប្រើប្រាស់អគ្គិសនីរបស់រដ្ឋ ដោយប្តូរមកជួលម៉ាស៊ីនភ្លើងប្រើវិញ។

២- ក្រុមហ៊ុនបានលក់វត្ថុធាតុដើម និងក្រណាត់ក្នុងឃ្លាំងអស់ ហើយបញ្ចូលវិញដោយយើប្រហែលជាច្រើនម៉ែត្រគូប(មានរូបថតជាភស្តុតាង)។

៣- ការយកលុយទៅបង្កើតរោងចក្រថ្មី ឈ្មោះ មីញ ហួយ (Ming Hui) ដោយយកឈ្មោះ Ly Zongming អតីតអ្នកជំនាញការចិនផ្នែកតុកាត់ ឱ្យមកឈរឈ្មោះជាម្ចាស់ក្រុមហ៊ុន ហើយខ្លួននៅពីក្រោយ។

៤- ការរករឿងកម្មករ ដើម្បីឱ្យផ្ទុះកូដកម្មខុសច្បាប់ និងឆ្លៀតឱកាសសុំបិទរោងចក្រ ដូចជាការប្តូរអគាររោងចក្រចុះឡើង និងការបើកប្រាក់ខែខ្វះ ជាច្រើនលើកច្រើនសារ។

៥- ការដកអ្នកធ្វើការសំខាន់ៗក្នុងការិយាល័យឱ្យទៅបំរើការនៅក្រុមហ៊ុន ស៊ូភើថិច និងការឱ្យអ្នកជំនាញការចិនទៅស្រុកវិញ។

៦- ការប្រមូល Order ទាំងអស់ទៅ ស៊ូភើថិច និង មីញ ហួយ ជាក់ស្តែង ដូចជាអ្នកបញ្ជាទិញVF ដែលជាអ្នកបញ្ជាទិញធំរបស់រោងចក្រ តាកហ្វាត កន្លងមក។

៧- ក្រុមហ៊ុនប្រគល់ការទទួលខុសត្រូវរោងចក្រ តាកហ្វាត ទៅឱ្យឈ្មោះTong Xuguong អតីតនាយកផលិតកម្ម ខណៈឈ្មោះ Tong Xuguong បានលាឈប់ពីការងារ តែក្រុមហ៊ុនមិនបើកប្រាក់ខែឱ្យជាច្រើនខែ។

៨- ការព្យួរការងារខុសច្បាប់ជាបន្តបន្ទាប់ ដោយប្រើរូបភាពគ្មានការងារធ្វើ តែធាតុពិតគឺមិនដាក់ការងារឱ្យ តាកហ្វាត ធ្វើ ខណៈដែលរោងចក្រ ស៊ូភើថិច និង មីញ ហួយ បន្ថែមម៉ោងដល់ម៉ោង ៨ និង ថ្ងៃអាទិត្យ។

៩- បងប្អូនតំណាងកម្មករនិយោជិត បដិសេធមិនទទួលយកប្រាក់ថ្លៃស្នាក់នៅចំនួន១២ដុល្លារ ក្នុងមួយខែ ដែលក្រុមហ៊ុនព្យួរការងាររយៈពេល ២ ខែ ចាប់ពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៩ ដល់ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៩។

ដោយឡែកភាគីក្រុមហ៊ុន តាកហ្វាត មិនឯកភាពដោះស្រាយតាមការទាមទារខាងលើរបស់បងប្អូនកម្មករនិយោជិតឡើយ (ឱ្យក្រុមហ៊ុនរំលាយកិច្ចសន្យាការងារកម្មករ ដោយផ្តល់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារ តាមមាត្រា ៧៥, ៧៧, ៨៩, ៩១, ១១៦, ១៦៦ និង ១៦៧ នៃច្បាប់ស្តីពីការងារ) ដោយហេតុថា:

ក-បញ្ហាវិវាទចុងក្រោយនេះ កើតឡើងដោយក្រុមហ៊ុនគ្មានការងារឱ្យកម្មករនិយោជិតធ្វើ ហើយនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ ក្រុមហ៊ុនបានសុំព្យួរការងារ ដោយដាក់ឱ្យនៅក្រោមការត្រួតពិនិត្យរបស់អធិការការងារ។ នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៩ អធិការកិច្ចការងារបានចុះទៅពិនិត្យ និងប្រជុំពិភាក្សាលើបញ្ហាប្រាក់ព្យួរការងារ

ដែលពេលនោះភាគីកម្មករនិយោជិត និងភាគីក្រុមហ៊ុនពុំបានឯកភាពគ្នាលើចំនួនប្រាក់នេះឡើយ ដោយកម្មករនិយោជិតទាមទារ ៥០ ភាគរយ ដូចដែលក្រុមហ៊ុនធ្លាប់ផ្តល់កន្លងមក តែដោយសារភាគីក្រុមហ៊ុនផ្តល់បានត្រឹមតែ ១០ ដុល្លារ ក្នុងមួយខែ ( ប្រាក់នេះ គិតទាំងប្រាក់ទ្រទ្រង់ជីវភាពផងដែរ) ។ ក្រោយមកវិវាទនេះ ក៏មានការសម្របសម្រួលដោយលោក កើត ជឿន និងលោក ខៀវ សារុធ ភាគីក្រុមហ៊ុនក៏បានបន្ថែមចំនួន២ដុល្លារទៀត គឺចុងក្រោយប្រាក់ថ្លៃស្នាក់នៅនៃការព្យួរកិច្ចសន្យាឡើងបាន ១២ ដុល្លារ ក្នុងមួយខែ ។

ខ-ក្រុមហ៊ុនក៏បានចេញសេចក្តីជូនដំណឹងចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៩ ដើម្បីបញ្ជាក់ពីជំហរទទួលខុសត្រូវរបស់ក្រុមហ៊ុនចំពោះបងប្អូនកម្មករនិយោជិត ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ( ខ)( មាត្រា ៣០៩ ដល់៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៥០ កប/ប្រក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ ( អាណត្តិទី៧) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ ( ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៩៨៩ កប/អក/វ.ក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩ វេលាម៉ោង ០២:០០ នាទី រសៀល ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងតាមរយៈទូរស័ព្ទរបស់កម្មករនិយោជិតស្តីពីក្ដួជកម្មទាមទារឱ្យក្រុមហ៊ុនរំលាយកិច្ចសន្យាការងារ ដោយតម្រូវឱ្យក្រុមហ៊ុនផ្តល់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាតាមច្បាប់ស្តីពីការងារ ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារ ប៉ុន្តែមិនបានទទួលលទ្ធផលសះជាទេ លើការទាមទារទាំងអស់ចំនួន ០១ ចំណុច ។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅ

ថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតមកជ្រើសរើសអាជ្ញាកណ្តាលនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ ដដែល ដើម្បីបង្កើតក្រុមអាជ្ញាកណ្តាល។ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩។ នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញបញ្ជាឱ្យកម្មករនិយោជិតផ្អាកកូដកម្មរហូតដល់នីតិវិធីអាជ្ញាកណ្តាលត្រូវបានបញ្ចប់សព្វគ្រប់ ។ ភាគីកម្មករនិយោជិតមិនស្តាប់តាមបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ នៅវេលាថ្ងៃដដែលនោះ ភាគីកម្មករនិយោជិតបានធ្វើលិខិតជំទាស់ទៅនឹងសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០១២/០៩ កបអ. ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ ។ បន្ទាប់ពីទទួលបានព័ត៌មានថា កម្មករនិយោជិតនៅតែបន្តកូដកម្ម លេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីកម្មករនិយោជិត និងនិយោជកមកជួបប្រជុំមុនសវនាការ ដើម្បីផ្តល់ព័ត៌មានទាក់ទងនឹងបញ្ហានេះនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ វេលាម៉ោង០៨:០០ នាទីព្រឹក ។ ភាគីទាំងពីរបានអញ្ជើញចូលរួមតាមការកោះហៅរបស់លេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

នៅក្នុងពេលជួបប្រជុំនោះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមពន្យល់ភាគីកម្មករនិយោជិតអំពីនីតិវិធីនៃការដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយបានស្នើសុំឱ្យភាគីកម្មករនិយោជិតផ្អាកកូដកម្មដោយរក្សាភាពស្ងៀមស្ងាត់ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលបន្តនីតិវិធីអាជ្ញាកណ្តាល។ ភាគីកម្មករនិយោជិតបានយល់ព្រមតាមការស្នើសុំរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយក៏មកចូលរួមសវនាការនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០០៩ នាវេលាម៉ោង ១៤:០០ នាទី ល្ងាច ។

នៅថ្ងៃសវនាការ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ មុននឹងបើកសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សាលើចំណុចវិវាទនេះអស់រយៈពេលជាច្រើនម៉ោង ប៉ុន្តែមិនបានទទួលលទ្ធផលសះជានឹងគ្នាឡើយ ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចបើកសវនាការ ប៉ុន្តែនៅពេលដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលចាប់ផ្តើមសវនាការ ភាគីកម្មករនិយោជិតបានជំទាស់ទៅនឹងសវនាការរបស់អាជ្ញាកណ្តាល ដោយលើកឡើងថា ក្នុងសំណុំរឿងនេះ ពួកគេពុំអាចចូលរួមសវនាការបានទេ ព្រោះលោកមេធាវី ដែលជាតំណាងរបស់ភាគីក្រុមហ៊ុននៅក្នុងសំណុំរឿងនេះ ពុំមានភាពតំណាងស្របច្បាប់ឡើយ ។ ភាគីកម្មករនិយោជិតបានលើកឡើងបន្ថែមទៀតថា ជាទូទៅ នៅពេលមានវិវាទកើតឡើង កម្មករនិយោជិតទាមទារទៅនិយោជក គឺត្រូវរកអ្នកទទួលខុសត្រូវពិតប្រាកដ ឬអ្នកតំណាងស្របច្បាប់មកដោះស្រាយ ។ ចំពោះក្រុមហ៊ុន ពាកប្លាត បច្ចុប្បន្ននេះ ភាគីកម្មករនិយោជិតពុំដឹងថា តើនរណាជាអ្នកទទួលខុសត្រូវពិតប្រាកដនៅក្នុងសំណុំរឿងនេះ តួយ៉ាងដូចជានៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន គឺមានឈ្មោះលោក **គុក វីង** ជាអ្នកគ្រប់គ្រង និងទទួលខុសត្រូវផ្ទាល់ ។ ក្រោយមកមានដំណឹងថា លោក **គុក វីង** មានបញ្ហានៅប្រទេសចិនក្នុងឆ្នាំ២០០៨ ឈ្មោះ

នេះត្រូវបានបាត់ពីក្រុមហ៊ុន តាកហ្វាត ក្នុងពេលនោះក៏មានអ្នកស្រី **ផេង ឌីង** បានចេញមុខមកទទួលខុសត្រូវនៅក្រុមហ៊ុននេះ បន្ទាប់មកទៀតមានឈ្មោះ **តុង ស៊ូគង** ដែលធ្លាប់មានមុខងារជាប្រធានផលិតកម្ម មកទទួលខុសត្រូវជានាយកក្រុមហ៊ុន ហើយចន្ទីមនឹងនេះនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន បែរជាឃើញឈ្មោះលោក **លី យ៉ុកមិន** ជានាយកក្រុមហ៊ុនវិញ។ សរុបទៅ កម្មករនិយោជិតពុំដឹងថា តើឈ្មោះអ្នកផ្ទេរសិទ្ធិជូនលោកមេធាវីដែលជាតំណាងមកដោះស្រាយនៅក្នុងសំណុំរឿងនេះជានរណាទេ។ ហេតុនេះហើយ ភាគីកម្មករនិយោជិតសម្រេចចិត្តមិនចូលរួមសវនាការបន្តទៀតទេ ។

ហេតុនេះហើយ នៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើសំណុំរឿងនេះ ដោយផ្អែកលើភស្តុតាង និង ហេតុផល ដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ចស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ Tong Xu Guang ជានាយកគ្រប់គ្រងក្រុមហ៊ុន តាកហ្វាត ប្រគល់សិទ្ធិជូនលោកមេធាវី ហំ ភា ដើម្បីដោះស្រាយវិវាទការងាររួម នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩។

២- វិញ្ញាបនប័ត្រចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន តាកហ្វាត ហ្គាមិន (ខេមបូឌា) អ៊ែរលធីឌី លេខ ៣១១៩ ពណ.ចបព ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨។

៣- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន តាកហ្វាត ហ្គាមិន (ខេមបូឌា) អ៊ែរលធីឌី លេខ ០០៧ សកបយ.អធក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៩។

៤- លក្ខន្តិកៈរបស់ក្រុមហ៊ុន តាកហ្វាត ហ្គាមិន (ខេមបូឌា) អ៊ែរលធីឌីចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៤។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- វិញ្ញាបនប័ត្រចុះបញ្ជីកាសហជីពសេរីកម្មករនៃរោងចក្រកាត់ដេរ តាកហ្វាត ហ្គាមិន ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩។

២- លិខិតរបស់លោកប្រធាននាយកដ្ឋានវិវាទការងារ ជម្រាបមក ប្រធានសហជីពកម្មករនិយោជិតរោងចក្រ តាកហ្វាត ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី លេខ ៩៧២ ករ/វក/វក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៨។

៣- លិខិតរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការស្នើសុំក្រុមហ៊ុន តាកហ្វាត បង្ហាញឯកសារផ្លូវច្បាប់ទាក់ទងនឹងអ្នក

ទទួលខុសត្រូវចំពោះក្រុមហ៊ុន តាកហ្វាត ។

៤- លិខិតរបស់តំណាងសហជីពទាំង ៧ ប្រចាំរោងចក្រ តាកហ្វាត ស្តីពីការជំទាស់នឹងសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលឱ្យផ្អាកកូដកម្ម ចាប់ពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន តាកហ្វាត លេខ ៩៨៩ កប/អក/វ.ក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន តាកហ្វាត ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- សេចក្តីបញ្ជាក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០១២/០៩ កបអ. ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ៧៦៦ កប/អក/វក/លកអ. ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩។

៣- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមផ្តល់ព័ត៌មាន លេខ ៧៦៧ កប/អក/វក/លកអ. ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩។

៤- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៧៧៤ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩។

៥- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៧៧៥ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩។

## អង្គហេតុ

-ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម

-ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក

-ក្រោយពីបានពិនិត្យឯកសារបន្ថែម

## ការរកឃើញអង្គហេតុ:

- ក្រុមហ៊ុន តាកហ្វាត មានទីតាំងនៅអគារលេខ ១១៩៩ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានជួលកម្មករនិយោជិតប្រមាណជិត ១.៨២៣ នាក់។
- សហជីព ដែលជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះមានចំនួន ៧ ដែលមានដូចជា សហជីពសេរីកម្មករ. សហជីពយុវជនខ្មែរ. សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ. សហជីពពន្លឺថ្មី. សហជីពកម្មករ

និយោជិត, សហជីពកម្មករអាស៊ី និងសហជីពអភិវឌ្ឍន៍កម្មករ ។

- អង្គហេតុទាក់ទងនឹងចំណុចវិវាទនេះគ្មានទេ ព្រោះក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនទាន់បានបើកសវនាការលើអង្គសេចក្តីនៅឡើយ ។

**ហេតុផលនៃសេចក្តីសម្រេច:**

ផ្អែកលើបញ្ហានៃនីតិវិធីខាងលើ ភាគីកម្មករនិយោជិតបានជំទាស់ទៅនឹងសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដោយលើកឡើងថា ក្នុងសំណុំរឿងនេះ ពួកគេមិនចូលរួមសវនាការទេ ព្រោះលោកមេធាវី ដែលជាតំណាងរបស់ក្រុមហ៊ុននៅក្នុងសំណុំរឿងនេះ ពុំមានភាពតំណាងស្របច្បាប់ ។ ហេតុដូច្នេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដោយយោងលើហេតុផលដូចខាងក្រោម:

ទាក់ទងនឹងការសម្រេចចិត្តមិនចូលរួមសវនាការនេះ វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ នេះចែងថា" *ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់* " ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានផ្តល់ជាជម្រើសឱ្យភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទនេះតាមនីតិវិធីច្បាប់ ។ ប៉ុន្តែសហជីពបានជ្រើសរើសការមិនចូលរួមសវនាការ ដោយលើកឡើងពីភាពជាតំណាងស្របច្បាប់របស់មេធាវី ដែលតំណាងឱ្យភាគីនិយោជក មានភាពមិនច្បាស់លាស់ ព្រោះឈ្មោះអ្នកផ្ទេរសិទ្ធិគឺ លោក **តុង ស៊ូតុង** មិនមានក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន តាកហ្វាត ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩ ទេ ទោះបីជាក្រុមប្រឹក្សាអាជ្ញាកណ្តាលបានស្នើសុំទុកពេលឱ្យមេធាវីតំណាងក្រុមហ៊ុនរកភស្តុតាង ដើម្បីបញ្ជាក់ពីភាពស្របច្បាប់នៃការតំណាងនេះក៏ដោយក៏ភាគីកម្មករនិយោជិតសម្រេចចិត្តមិនចូលរួមសវនាការបន្តទៀតដែរ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មិនចូលរួមសវនាការមុនដំណើរការក្រុមប្រឹក្សាអាជ្ញាកណ្តាលលើអង្គសេចក្តីបានចាប់ចាប់ផ្តើម អាចចាត់ទុកថា ជាការមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងរបស់ភាគីដើមបណ្តឹង នៅក្នុងដំណើរការអាជ្ញាកណ្តាល ។ ផ្អែកលើវិធានខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្តាល *អាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់* ។

ហេតុដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បិទសំណុំរឿងនេះ ។

យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច :

**<u>សម្រេច និង បង្គាប់</u>**

- បិទសំណុំរឿងលេខ ១៤៧/០៩-ក្រុមហ៊ុន តាកហ្វាត នេះ ។

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **កៅ ថាច**

ហត្ថលេខា: ---------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ម៉ែន ពៅ**

ហត្ថលេខា: ---------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: ---------------------------------